雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.148

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7593 ថ្ងៃសុក្រ ទី 23 ខែ មីនា ឆ្នាំ 2018


## វប្បធម៌ខេត្តយូនណានមានឈ្មោះល្បីល្បាញលើពិភពលោក



*រូបថតឆាកមួយនៃកម្មវិធី សម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" ដែលជាកម្មវិធីវប្បធម៌មួយដែលចូលរួមដំណើការដោយកម្ពុជា និង ខេត្តយូនណានរបស់ចិន (រូបថតដោយ Wang Bangxu )*

នៅឆ្នាំ២០១១ កម្មវិធីសម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" ដែលរៀបចំដោយក្រុមហ៊ុនវិនិយោគវប្បធម៌ខេត្តយូនណាន និងស្ថាប័នវប្បធម៌នៃប្រទេសកម្ពុជា បានត្រូវសម្តែងជាលើកដំបូងនៅតំបន់អង្គរនៃប្រទេសកម្ពុជា ។ គិតមកដល់ពេលនេះ កម្មវិធី "ស្នាមញញឹមអង្គរ "នេះ បានសម្តែងជាង ២.០០០លើកនៅប្រទេសកម្ពុជាដែលបានទទួលនូវចំណូលជាង២០០ លានយ័នប្រាក់ចិន ហើយបានទទួលរង្វាន់រួមវិភាគទានសេវាកម្មទេសចរណ៍ពិសេសដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា។ ភាគីទាំងពីរចិន និងកម្ពុជារួមសហការគ្នាយ៉ាងស្អិតល្មួត។ក្រុមហ៊ុនចិនបណ្តាក់ទុនវិនិយោគ ឯតួសម្តែងខ្មែរចូលរួមកម្មវិធីសម្តែងដែលបានធ្វើឱ្យទស្សនិកជនទូទាំងពិភពលោកស្គាល់កាន់តែច្បាស់នូវសម្រស់ស្អាតនៃវប្បធម៌ខ្មែរ។ នេះបានបង្ហាញពីខ្លឹមសារសំខាន់នៃគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយនិងផ្លូវមួយ" គឺ "រួមគ្នាពិគ្រោះពិភាក្សាស្ថាបនា និងចែករំលែកគ្នា"។

លោកថាវ ឈុន តំណាងរាស្ត្រនៃសភាតំណាងប្រជាជនទូទាំងប្រទេសចិនអ្នកត្រួតពិនិត្យរួមផ្នែកសិល្បៈនិងជាអ្នកដឹកនាំកម្មវិធី "ស្នាមញញឹមអង្គរ" បានលើកឡើងថា កម្មវិធីសម្តែង "ស្នាមញញឹមអង្គរ" បានបង្ហាញយ៉ាងពេញលេញអំពីកត្តាវប្បធម៌ខ្មែរ និងមនោសញ្ចេតនារបស់ប្រទេសចិនដែលរាប់អានគ្នាជាមួយប្រទេសកម្ពុជា ។ ខេត្តយូនណាន បាននិងកំពុងដើរតួនាទីសំខាន់ក្នុងការកសាង "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ចំណែកការផ្លាស់ប្តូរវប្បធម៌ជាមធ្យោបាយដ៏សំខាន់សម្រាប់បង្កើនទំនាក់ទំនងរវាងបណ្តាប្រទេសនានា ។ ដូច្នេះយើងទាំងអស់គ្នាត្រូវខិតខំបង្កើនការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌ "ខ្សែក្រវាត់មួយនិងផ្លូវមួយ "ព្រមទាំងជំរុញការតភ្ជាប់ក្រអៅបេះដូងរបស់ប្រជាជននៃប្រទេសទាំងពីរទើបអាចធ្វើឱ្យ" ខ្សែក្រវាត់មួយនិងផ្លូវមួយ" ទទួលបានសមិទ្ធផលជាក់ស្តែងកាន់តែច្រើនថែមទៀត ។

លោកលី គួវៃ ជាអ្នកទទួលនិងផ្សព្វផ្សាយសិប្បកម្មធ្វើគ្រាប់អុក "យ៉ុងជី" ។ លោកជាអ្នកបន្តវេនរបស់លោកលីតឺ ជាំង ដែលជាស្ថាបនិកនៃសិប្បកម្មប្រពៃណីនេះ ។ លោកបានបញ្ជាក់ថា អុក "វៃឈី" គឺជាស្នាដៃប្រណីតរបស់ជនជាតិចិននិងមានប្រភពពីអរិយធម៌និងក្តីប្រាថ្នារបស់ជនជាតិចិន ។ "យ៉ុងជី" គឺជារតនវត្ថុផ្នែកវប្បធម៌ដ៏សំខាន់សម្រាប់ផ្សព្វផ្សាយវប្បធម៌ប្រពៃណីចិនហើយក៏ជាធនធានវប្បធម៌និងម៉ាកវប្បធម៌ដ៏មានតម្លៃរបស់យើង ។ ការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅអំពីតម្លៃវប្បធម៌ទេសចរណ៍កីឡានិងសេដ្ឋកិច្ចរបស់គ្រាប់អុក "យ៉ុងជី" នេះនឹងអាចធ្វើឱ្យវប្បធម៌ចិនមានខ្លឹមសារកាន់តែសម្បូរព្រមទាំងធ្វើឱ្យប្រជាជន នៃបណ្តាប្រទេសនានាមានការយល់ដឹងកាន់តែច្បាស់និងកាន់តែស៊ីជម្រៅអំពីវប្បធម៌ចិន ៕

**ដោយ យ៉ាងជីហ្វួយ**

## ប្រទេសចិនកំពុងធ្វើដំណើរតាមផ្លូវត្រឹមត្រូវសម្រាប់ ជំរុញការអភិវឌ្ឍបុព្វហេតុកាត់បន្ថយភាពក្រីក្រ



*មណ្ឌលស្វយ័តជនជាតិភីបេត៍ ភីឈាង ដែលស្ថិតនៅភាគីពាយ័ព្យ នៃខេត្តយូនណាន គឺជាមរណីដ្ឋាន អភិវឌ្ឍន៍ទេសចរណ៍ដ៏ចម្បងនៅក្នុងខេត្តយូនណានកំពុងតែបង្កើនប្រាក់ ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន (រូបថត ដោយ Zhang Tong )*

ក្នុងកិច្ចប្រជុំសភាតំណាងប្រជាជន និងសភាប្រឹក្សានយោបាយប្រជាជនទូទាំងប្រទេសចិនដែលរៀបចំនៅឆ្នាំ ២០១៨ នេះ ការកាត់បន្ថយភាពក្រីក្រគឺជាបញ្ហាក្តៅគគុកដ៏សំខាន់ដែលបានទទួលនូវការចាប់អារម្មណ៍ពីអង្គប្រជុំ។ ប្រទេសចិនបានលើកឡើងនូវគោលដៅប្រចាំឆ្នាំ២០២០ ថា ប្រទេសចិននឹងកាត់បន្ថយភាពក្រីក្រទាំងស្រុងនៅតាមតំបន់ជនបទ ។ ទោះបីជាប្រទេសចិនកំពុងប្រឈមនឹងក្តីលំបាកដ៏ច្រើនក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏ប៉ុន្តែសហគមន៍អន្តរជាតិនៅតែមានជំនឿយ៉ាងមុតមាំថាគោលដៅដែលកំណត់ដោយរដ្ឋាភិបាលចិន គឺជាគោលដៅដែលអាចសម្រេចបាន ។ ប្រទេសចិនកំពុងធ្វើដំណើរតាមផ្លូវត្រឹមត្រូវសម្រាប់ជំរុញការអភិវឌ្ឍបុព្វហេតុកាត់បន្ថយភាពក្រីក្រចំណែកសមិទ្ធផលរបស់ប្រទេសចិននឹងអាចលើកទឹកចិត្តឱ្យប្រទេសផ្សេងៗទៀតខិតខំជំរុញការអភិវឌ្ឍន៍នៃបុព្វហេតុកាត់បន្ថយភាពក្រីក្រឱ្យទទួលបាននូវសមិទ្ធផលកាន់តែច្រើនថែមទៀត។

កាសែត "IndianExpress" បានចុះផ្សាយអត្ថបទថា រដ្ឋាភិបាលចិនផ្តោតការយកចិត្តទុកដាក់ទៅលើគោលការណ៍ដែលចាត់ទុកមនុស្សជាមូលដ្ឋាន ហើយបានទទួលសមិទ្ធផលដ៏ច្រើនគួរឱ្យកត់សម្គាល់ ។ រដ្ឋាភិបាលចិនបានធ្វើឱ្យប្រជាជនរាប់សិបលាននាក់ជៀសផុតពីការអត់ឃ្លាននិងភាពក្រីក្រតែប្រទេសច្រើនដែលមានស្ថានការណ៍ស្រដៀងនឹងប្រទេសចិននៅមិនទាន់ទទួលនូវសមិទ្ធផលដូចប្រទេសចិនក្នុងកិច្ចកាត់បន្ថយភាពក្រីក្រទេ ។

លោកណាពីលី ហ្សាគី អ្នកនាំពាក្យនៃគណបក្សរួបរួមជាតិនិងរីកចម្រើនប្រទេសជាតិអេហ្ស៊ីបបានមានប្រសាសន៍ថា ប្រទេសចិនកំពុងជំរុញការធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ។ ទន្ទឹមនឹងនេះការកាត់បន្ថយភាពក្រីក្រនឹងក្លាយទៅជាមធ្យោបាយដ៏សំខាន់សម្រាប់លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន ។ បទពិសោធន៍របស់ចិននឹង អាចផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសនានាលើពិភពលោកដូច្នេះ មានប្រទេសច្រើនកំពុងតែសិក្សាស្រាវជ្រាវ និងរៀនសូត្រអំពីបទពិសោធន៍របស់ប្រទេសចិន ។

លោកស៊ូមូយ៉ា ចាទូផាយៀ អ្នកជំនាញការនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវបញ្ហានាយសមុទ្រប្រទេសអង់គ្លេសបានបញ្ជាក់ថាបុព្វហេតុកាត់បន្ថយភាពក្រីក្ររបស់ប្រទេសចិនមានឧត្តមភាពសំខាន់លើវិស័យ២ គឺ១- ប្រទេសចិនបានរក្សាកំណើនសេដ្ឋកិច្ចដែលមានល្បឿនយ៉ាងលឿន។ នេះបានធ្វើឱ្យការងារកាត់បន្ថយភាពក្រីក្ររបស់ចិនអាចប្រមូលបានថវិកាគ្រប់គ្រាន់ ។ ២- ប្រទេសចិនមានស្ថិរភាពនយោបាយដែលអាចរក្សាស្ថិរភាពនិងនិរន្តរភាពក្នុងការកំណត់និងអនុវត្តគោលនយោបាយអំពីកិច្ចកាត់បន្ថយភាពក្រីក្រ ។ ប្រទេសចិនបានទទួលសមិទ្ធផលដ៏ច្រើនក្នុងការអភិវឌ្ឍបុព្វហេតុកាត់បន្ថយភាពក្រីក្រចំណែកបទពិសោធន៍របស់ប្រទេសចិនបានផ្តល់នូវគំរូដ៏ល្អប្រសើរមួយដល់ប្រទេសផ្សេងៗលើពិភពលោក។

លោកលី យឺនលាំង អ្នកសិក្សាស្រាវជ្រាវអំពីបញ្ហាអន្តរជាតិ នៃវិទ្យាស្ថានអភិវឌ្ឍន៍រដ្ឋបាលជាតិប្រទេស ថៃ បានពន្យល់ថា សមិទ្ធផល ដែលប្រទេសចិនទទួលបានក្នុងការ អភិវឌ្ឍបុព្វហេតុកាត់បន្ថយភាពក្រីក្រ នោះបានបង្ហាញឱ្យឃើញពីទស្សនៈគ្រប់គ្រងប្រទេសដែលចាត់ទុកមនុស្សជា មូលដ្ឋាន ។ បើគិតតាមល្បឿននៃការ អនុវត្តការងារកាត់បន្ថយភាពក្រីក្ររបស់ប្រទេសចិននៅឆ្នាំ២០២០ ប្រទេស ចិននឹងអាចដោះស្រាយទាំងស្រុងនូវបញ្ហាក្រីក្រ ។ ប្រទេសថៃគួរតែរៀនបទពិសោធន៍ដ៏ជោគជ័យពីប្រទេសចិនរួម មានគោលនយបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសនិងបទពិសោធន៍ដ៏ មានតម្លៃមួយចំនួនទៀត ៕ **(ស៊ីនហួចិន)**

## ខេត្តយូនណានបង្កើត "វិទ្យាស្ថានផ្សព្វផ្សាយព័ត៌មានអន្តរជាតិ "

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ ២០១៨ វិទ្យាស្ថានផ្សព្វផ្សាយព័ត៌មានអន្តរជាតិដែលរួមគ្នាបង្កើតដោយក្រុមហ៊ុនកាសែតយូនណានដេលីគ្រុបនិងសាកលវិទ្យាល័យគរុកោសល្យខេត្តយូនណាន នោះ បានត្រូវបង្កើតឡើង ជាផ្លូវការនៅខណ្ឌឈឺងកុងនៃខេត្តយូនណាន ។

ក្រោយពីវិទ្យាស្ថានផ្សព្វផ្សាយព័ត៌មានអន្តរជាតិនេះ ត្រូវបានបង្កើតឡើងក្រុមហ៊ុនកាសែតយូនណាន ដេលីគ្រុប និងសាកលវិទ្យាល័យគរុកោសល្យខេត្តយូនណាននឹងអាចរួមសហការគ្នានិងបំពេញបន្ថែមគ្នាលើវិស័យធនធានព័ត៌មាន និងអប់រំដែលនឹងអាចបំពេញតម្រូវការនៃការបណ្តុះបណ្តាលធនធានមនុស្សផ្នែកសារព័ត៌មាន។ កិច្ចសហប្រតិបត្តិការរវាងកាសែតយូនណានដេលីនិងសាកលវិទ្យាល័យគរុកោសល្យខេត្តយូនណានបានជំរុញការអប់រំក្នុងសាលារៀន និងការអនុវត្តជាក់ស្តែងការសិក្សាស្រាវជ្រាវ និងការច្នៃប្រឌិតបច្ចេកទេសឈានមុន និងប្រព័ន្ធមីឌាការបណ្តុះបណ្តាលធនធានមនុស្សនិងការអភិវឌ្ឍបណ្តាញសារព័ត៌មានឱ្យតភ្ជាប់គ្នាយ៉ាងស៊ីជម្រៅ និងស៊ីសង្វាក់គ្នាកម្រិតខ្ពស់ ដើម្បីបណ្តុះបណ្តាលធនធានមនុស្សផ្នែកសារព័ត៌មានដែលចេះនិយាយភាសាចិន និងភាសាប្រទេសអាស៊ីអាគ្នេយ៍ ព្រមទាំងបង្កើតវិទ្យាស្ថានផ្សព្វផ្សាយព័ត៌មានជាន់ខ្ពស់មួយដែលបើកចំហចំពោះតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ៕

**ដោយ ឈឺន យីស៊ី**

## ខេត្តយូនណានបណ្តុះបណ្តាលនិស្សិតបរទេសរៀនពេទ្យចិនសែជាង២.០០០នាក់

តាមប្រភពព័ត៌មានពីគណៈកម្មាធិការសុខាភិបាល និងសម្រាលកូនតាមផែនការរបស់ខេត្តយូនណាន បានឱ្យដឹងថា គិតមកដល់ពេលនេះ វិទ្យាស្ថានពេទ្យចិនសែខេត្តយូនណានបានបណ្តុះបណ្តាលនិស្សិតបរទេសជាង២.០០០នាក់ ដែលរៀនមុខវិជ្ជាអំពីពេទ្យចិនសែ ហើយបានបង្កើតមជ្ឈមណ្ឌលពេទ្យចិនសែនៅប្រទេសឡាវ និងកាណាដាជាដើម ។

នៅឆ្នាំ២០១៥ ខេត្តយូនណានបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលពេទ្យចិនសែប្រទេសឡាវនៃវិទ្យាស្ថានពេទ្យចិនសែខេត្តយូនណាន ហើយបានបង្កើតមជ្ឈមណ្ឌលពេទ្យចិនសែប្រទេសកាណាដានៃវិទ្យាស្ថានពេទ្យចិនសែខេត្តយូនណាន។ នៅខែកញ្ញា ឆ្នាំ ២០១៦ កិច្ចប្រជុំពេទ្យបុរាណប្រទេសទន្លេឡានឆាង-មេគង្គលើកទី១ បានត្រូវរៀបចំដោយជោគជ័យហើយបានបង្កើតវិទ្យាស្ថានពេទ្យបុរាណទន្លេឡានឆាង-មេគង្គនៅក្នុងវិទ្យាស្ថានពេទ្យចិនសែខេត្តយូនណានដើម្បីពង្រឹងឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យពេទ្យបុរាណរវាងប្រទេសចិនជាមួយប្រទេសតាមបណ្តោយទន្លេឡានឆាង-មេគង្គ ក៏ដូចជាប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងផ្សេងៗផងដែរ។

គិតមកដល់ពេលនេះ វិទ្យាស្ថានពេទ្យចិនសែខេត្តយូនណានបានបង្កើតទំនាក់ទំនងផ្លាស់ប្តូរគ្នា និងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ ជាមួយប្រទេសនិងតំបន់ចំនួនជាង៣០លើពិភពលោក រួមមានប្រទេសអូស្ត្រាលីបារាំង អាល្លឺម៉ង់ កាណាដា ស្វីស កូរ៉េខាងត្បូង ថៃ វៀតណាមនិងឥណ្ឌូណេស៊ីជាដើមហើយបានបណ្តុះបណ្តាលនិស្សិតបរទេសជាង២.០០០នាក់ដែលរៀនមុខវិជ្ជាអំពីពេទ្យចិនសែ៕ **ដោយឈឺនជឹង**

## ខ្សែភាពយន្តយូនណាន "ទាហានចចកស្រែកយំ " បាន ត្រូវលើកឈ្មោះដណ្តើមរង្វាន់ទិវាភាពយន្តអាមេរិក




*ផ្ទាំងផូស្ទ័រ នៃភាពយន្តអំពី ខេត្តយូនណាន ដែលមានចំណងជើងថា "ទាហានចចកស្រែកយំ" (រូបថត ដោយ Li Yuechun )*

ក្នុងទិវាភាពយន្តអន្តរជាតិរដូវរងាក្រុងញូវយ៉កលើកទី៧ ដែលរៀបចំនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨ ខ្សែភាពយន្តខេត្តយូនណានឈ្មោះ "ទាហានចចកស្រែកយំ" បានត្រូវលើកឈ្មោះដណ្តើមរង្វាន់ពីរ គឺរង្វាន់ភាពយន្តល្អបំផុត និងតួសម្តែងស្ត្រីល្អបំផុត។

ក្នុងទិវាភាពយន្តនេះខ្សែភាពយន្ត "ទាហានចចកស្រែកយំ" បានត្រូវគណៈកម្មការជ្រើសរើសឱ្យចាក់បញ្ចាំងមុនគេនៅទ្វីបអាមេរិកខាងជើង ពោលគឺចាក់បញ្ចាំងជាលើកដំបូងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។ ប្រព័ន្ធផ្សព្វផ្សាយអាមេរិកបានធ្វើសម្ភាសន៍ពិសេស៣ លើកជាមួយលោក វ៉ាង យ៉ុង និងអ្នកផលិតសំខាន់ៗជាច្រើនរូបទៀតនៃខ្សែភាពយន្តនេះ ដើម្បីស្វែងយល់អំពីប្រភពរឿង និងតួអង្គផ្សេងៗក្នុងភាពយន្តនេះ។ គួរបញ្ជាក់ថា ខ្សែភាពយន្តនេះបានត្រូវលើកឈ្មោះឱ្យទៅដណ្តើមរង្វាន់ភាពយន្តល្អបំផុតចំណែកកញ្ញា សៀ តុងមុី ដែលជាតួសម្តែងសំខាន់នៃភាពយន្តនេះបានត្រូវគេលើកឈ្មោះឱ្យទៅដណ្តើមរង្វាន់តួសម្តែងស្ត្រីល្អបំផុតក្នុងទិវាភាពយន្តអន្តរជាតិនេះ៕ **ដោយ លី យៀឈុន**